# ការទទួលបានច្បាប់ឈប់សម្រាកឈឺ

## សេចក្ដីជូនដំណឹងអំពីសិទ្ធិរបស់និយោជិត

## ចូលជាធរមានចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023

CITY OF BLOOMINGTON MINNESOTA

<u>បទបញ្ញត្តិស្ដីពីការទទួលបានច្បាប់ឈប់សម្រាកឈឺ (ESSL) តម្រូវឱ្យនិយោជកផ្ដល់ច្បាប់ឈប់សម្រាកឈឺ ដោយមានប្រាក់ឈ្នួលសម្រាប់និយោជិតដែលធ្វើការក្នុងទីក្រុង Bloomington។</u>

**អ្នកមានសិទ្ធិក្នុងការទទួលបានច្បាប់ឈប់សម្រាកឈឺ ដែលអ្នកអាចប្រើដើម្បីឈប់សម្រាកថែទាំព្យាបាល ឬដើម្បីសុវត្ថិភាពរបស់អ្នក ឬសមាជិកក្រុមគ្រួសារ។**

### តើនរណាមានលក្ខណសម្បត្តិគ្រប់គ្រាន់?

និយោជិតដែលធ្វើការក្នុងទីក្រុង Bloomington រយៈពេល 80 ម៉ោងឡើងទៅក្នុងមួយឆ្នាំ។ និយោជិតអាចជាអ្នកធ្វើការពេញម៉ោង ក្រៅម៉ោង បណ្ដោះអាសន្ន ឬតាមរដូវកាល។

### ចំពោះច្បាប់ឈប់សម្រាក ដែលមិនបានប្រើត្រូវទូទាត់ដូចម្ដេច?

ច្បាប់ ESSL ត្រូវតែទូទាត់ប្រាក់នៅថ្ងៃកំណត់តែមួយ និងតាមអត្រាដូចគ្នានឹងប្រាក់ឈ្នួលធម្មតា។

### តើខ្ញុំទទួលបានច្បាប់ឈប់សម្រាកដោយរបៀបណា?

ទទួលបានមួយម៉ោងនៃច្បាប់ ESSL រាល់ 30 ម៉ោងដែលបានធ្វើការ។

និយោជិតអាចទទួលបានរហូតដល់ 48 ម៉ោង/ឆ្នាំ។

ច្បាប់ ESSL ដែលមិនបានប្រើប្រាស់អាចលើកទៅប្រើ ឆ្នាំក្រោយ។

### ឆែកមើលចុងសន្លឹកប័ណ្ណបើកខែប្រាក់របស់អ្នក

និយោជិតត្រូវតែកត់ចំនួនច្បាប់ឈប់សម្រាកឈឺ ដែលទទួលបាននៅលើចុងសន្លឹកប័ណ្ណបើកខែប្រាក់របស់អ្នក។



### តើច្បាប់ឈប់សម្រាកអាចប្រើប្រាស់នៅពេលណា និងដោយរបៀបណា?

និយោជិតអាចប្រើប្រាស់ច្បាប់ឈប់សម្រាក(ក) សម្រាប់តម្រូវការផ្នែកវេជ្ជសាស្ត្រ ផ្លូវកាយ ផ្លូវចិត្ត ឬសុខភាព (ខ) សម្រាប់ការបិទសាលារៀន ឬបិទកន្លែងធ្វើការ និង (គ) នៅពេលដែលពួកគេ ឬសមាជិកគ្រួសារគឺជាជនរងគ្រោះនៃករណីអំពើហិង្សាក្នុងគ្រួសារ រំលោភបំពានផ្លូវភេទ ឬដើរតាមរំខាន។

ការសងសឹកលើនិយោជិតដែលព្យាយាមប្រើច្បាប់ ESSL ត្រូវបានហាមឃាត់។ យោជិតអាចដាក់ពាក្យប្ដឹងនិយោជកដែលសងសឹកលើនិយោជិត ឬមិនផ្ដល់ច្បាប់ ESSL ឱ្យ។

ប្រសិនបើអ្នកជឿជាក់ថាសិទ្ធិរបស់អ្នកក្នុងការទទួលបានច្បាប់ ESSL ត្រូវបានបំពាន អ្នកអាចដាក់ពាក្យបណ្ដឹងនៅ៖

អ៊ីមែល៖ ESSL@bloomingtonmn.gov • គេហទំព័រ៖ blm.mn/essl • លេខទូរសព្ទ៖ 952-563-8753

តាមសំបុត្រ/ដោយផ្ទាល់៖ City of Bloomington, Legal Department, Compliance Division, 1800 W. Old Shakopee Road, Bloomington, MN 55431

**ស្កេន QR ខាងក្រោម សម្រាប់ព័ត៌មានបន្ថែម។**

សេចក្ដីជូនដំណឹងដែលច្បាប់តម្រូវឲ្យបិទនៅទីតាំងដែលនិយោជិតអាចមើលឃើញច្បាស់។